# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

លេខ ១៤១ សសរ.កសក

# សេចក្តីសម្រេច
## ស្តីពី
## របៀបរបបការងារនិងការបែងចែកភារកិច្ច
## របស់ថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៨/៩២៥ ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៦១៨/០១២ ចុះថ្ងៃទី២៨ ខែមិថុនា ឆ្នាំ២០១៨ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឲ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១០៥ អនក្រ.បក ចុះថ្ងៃទី២២ ខែសីហា ឆ្នាំ២០០៥ ស្តីពីការបន្ថែមមុខងារភារកិច្ចឲ្យក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងការបង្កើតនាយកដ្ឋានសវនកម្មផ្ទៃក្នុង នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ចំណុះក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួង ទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឲ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឲ្យទៅជាអគ្គនាយដ្ឋានកសិកម្ម និងការកែសម្រួលអគ្គ-នាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ២២៤ អនក្រ.បក ចុះថ្ងៃទី២៨ ខែតុលា ឆ្នាំ២០១៦ ស្តីពីការដំឡើងនាយកដ្ឋានផលិតកម្ម និងបសុព្យាបាល ទៅជាអគ្គនាយកដ្ឋានសុខភាពសត្វនិងផលិតកម្មសត្វ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

# **សម្រេច**

**ប្រការ១ .-**

កំណត់របៀបរបបការងារនិងបែងចែកភារកិច្ចជូនថ្នាក់ដឹកនាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ សំដៅធានាការអនុវត្តច្បាប់លិខិតបទដ្ឋានរបស់រាជរដ្ឋាភិបាលនិងដឹកនាំរាល់កិច្ចការនិងសកម្មភាពរបស់ក្រសួងលើវិស័យកសិកម្ម។

**ប្រការ២ .-**

ឯកឧត្តម **វេង សាខុន** រដ្ឋមន្ត្រីទទួលបន្ទុកដឹកនាំការងាររួមរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ និងចាត់ចែងបញ្ហារាល់សកម្មភាពរបស់ក្រសួង។

**ប្រការ៣ .-**

ចំពោះរដ្ឋលេខាធិការនិងអនុរដ្ឋលេខាធិការ

១.ឯកឧត្តម **នុត ច័ន្ទសុខា** រដ្ឋលេខាធិការប្រចាំការ បំពេញភារកិច្ចតាមស្មារតីអនុក្រឹត្យលេខ១១៨ អនក្រ.បក ចុះថ្ងៃទី០៦ ខែកញ្ញា ឆ្នាំ២០១៨ និងជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពត និងខេត្តកែប។

២.ឯកឧត្តម **យុទ្ធ ភូថង** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកោះកុង និងខេត្តព្រះសីហនុ។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **យុទ្ធ ភូថង** មានឯកឧត្តម **ហៃ រស្មី** អនុរដ្ឋលេខាធិការ ជាជំនួយការនិងទទួលបន្ទុកលើការងារលទ្ធកម្ម។

៣.ឯកឧត្តម **ឱម គីមស៊ា** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារសាកលវិទ្យាល័យភូមិន្ទកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ឆ្នាំង។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ឱម គីមស៊ា** មានលោកជំទាវ **យើ្យ អាស៊ីគីន** អនុរដ្ឋលេខាធិការ ជាជំនួយការ។

៤.ឯកឧត្តម **ម៉ម អំណាត់** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារអគ្គនាយកដ្ឋានកសិកម្ម វិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តតាកែវ និងខេត្តបន្ទាយមានជ័យ។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ម៉ម អំណាត់** មានអនុរដ្ឋលេខាធិការចំនួន០៤រូបជាជំនួយការៈ

១)-ឯកឧត្តម **អ៊ឹង ហុកលីម** អនុរដ្ឋលេខាធិការ ទទួលបន្ទុកនាយកដ្ឋានគ្រប់គ្រងធនធានដីកសិកម្ម និងមន្ទីរពិសោធន៍ជាតិកសិកម្ម

២)-លោកជំទាវ **ចាន់ ផលឿន** អនុរដ្ឋលេខាធិការ ទទួលបន្ទុកវិទ្យាស្ថានស្រាវជ្រាវនិងអភិវឌ្ឍន៍កសិកម្មកម្ពុជា នាយកដ្ឋានការពារដំណាំ អនាម័យនិងភូតគាមអនាម័យ

៣)-ឯកឧត្តម **ម៉ៅ រិទ្ធីថា** អនុរដ្ឋលេខាធិការ ទទួលបន្ទុកនាយកដ្ឋានដំណាំឧស្សាហកម្ម និងនាយកដ្ឋានវិស្វកម្មកសិកម្ម

៤)-ឯកឧត្តម **ឈុំ នុនលី** អនុរដ្ឋលេខាធិការ ទទួលបន្ទុកនាយកដ្ឋានដំណាំស្រូវ និងនាយកដ្ឋានសាកវប្បកម្មនិងដំណាំរួមផ្សំ។

៥.លោកជំទាវ **ហោ ម៉ាលីន** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារអគ្គនាយកដ្ឋានសុខភាពសត្វ និងផលិតកម្មសត្វ ការងារយេនឌ័រ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ស្ពឺ។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ លោកជំទាវ **ហោ ម៉ាលីន** មានឯកឧត្តម **ភៅ ផល** អនុរដ្ឋលេខាធិការ ជាជំនួយការ។

៦.ឯកឧត្តម **ណៅ ធូក** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកជាប្រធានអាជ្ញាធរគ្រប់គ្រងនៃអនុសញ្ញាស្តីពីពាណិជ្ជកម្មអន្តរជាតិលើប្រភេទសត្វនិងរុក្ខជាតិព្រៃដែលជិតផុតពូជ(CITES) ស្នងការតំណាងកម្ពុជាប្រចាំគណៈកម្មាធិការនេសាទបាឡែនអន្តរជាតិ (Commissioner for Cambodia to International Whaling Commission) ទទួលបេសកកម្មពិសេសបង្ក្រាបបទល្មើសនេសាទ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តសៀមរាប។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ណៅ ធូក** មានឯកឧត្តម **សៅ វណ្ណសិរីវុទ្ធ** អនុរដ្ឋលេខាធិការ ជាជំនួយការ។

៧.ឯកឧត្តម **លី ផល្លា** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានកសិ-ឧស្សាហកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តក្រចេះ និងខេត្តស្ទឹងត្រែង។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **លី ផល្លា** មានឯកឧត្តម **ចាន់ ចេស្តា** អនុរដ្ឋលេខាធិការ ជាជំនួយការ។

៨.ឯកឧត្តម **ហាស់ សារ៉េត** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងាររដ្ឋបាលជលផល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រៃវែង។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ហាស់ សារ៉េត** មានឯកឧត្តម **ឃុន សាវឿន** អនុរដ្ឋលេខាធិការ ជាជំនួយការ។

៩.ឯកឧត្តម **ហ៊ាន វណ្ណហាន** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកសហប្រធានក្រុមការងារបច្ចេកទេសកសិកម្មនិងទឹក នាយកដ្ឋានផែនការនិងស្ថិតិ នាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តរតនគិរី។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ហ៊ាន វណ្ណហាន** មានអនុរដ្ឋលេខាធិការចំនួន០២រូបជាជំនួយការៈ

១)-ឯកឧត្តម **សាន វណ្ណធី** អនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានសហប្រតិបត្តិការអន្តរជាតិ

២)-ឯកឧត្តម **គិត សេង** អនុរដ្ឋលេខាធិការទទួលបន្ទុកនាយកដ្ឋានផែនការនិងស្ថិតិ។

១០.ឯកឧត្តម **អ៊ុង សំអាត** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងាររដ្ឋបាលព្រៃឈើ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ចាម។

១១.ឯកឧត្តម **សេន សុវណ្ណ** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានកិច្ចការរដ្ឋបាល និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តមណ្ឌលគិរី។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **សេន សុវណ្ណ** មានឯកឧត្តម **គង់ ចាន់** អនុរដ្ឋលេខាធិការ ជាជំនួយការ។

១២.ឯកឧត្តម **ម៉ាន សុត្រី** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារអគ្គនាយកដ្ឋានកៅស៊ូ និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តកំពង់ធំ។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ម៉ាន សុត្រី** មានឯកឧត្តម **រស់ សូដែន** អនុរដ្ឋលេខាធិការ ជាជំនួយការ។

១៣.ឯកឧត្តម **ឆេង គឹមស៊ុន** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើសាលាជាតិកសិកម្មព្រែកលៀប សាលាជាតិកសិកម្មកំពង់ចាម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តឧត្តរមានជ័យ។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ឆេង គឹមស៊ុន** មានឯកឧត្តម **អ៊ុង កុសល** អនុរដ្ឋលេខាធិការ ជាជំនួយការ។

១៤.ឯកឧត្តម **ចាន់ សុខុន្ធ** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារលេខាធិការដ្ឋានបច្ចេកទេសសម្រាប់សម្បទានដីសេដ្ឋកិច្ច និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តបាត់ដំបង និងខេត្តប៉ៃលិន។

១៥.ឯកឧត្តម **គុយ ម៉ារិនឌី** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារកំណែទម្រង់វិមជ្ឈការ និងវិសហមជ្ឈការប្រចាំក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ការប្រមូលចំណូលសម្បទានដីសេដ្ឋកិច្ច និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តព្រះវិហារ។

១៦.ឯកឧត្តម **គឹម សុន** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋាននីតិកម្មកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តស្វាយរៀង។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **គឹម សុន** មានឯកឧត្តម **ឡោ ស្មើ** អនុរដ្ឋលេខាធិការ ជាជំនួយការ។

១៧.ឯកឧត្តម **តូច ម៉ុនហួរ** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទខេត្តពោធិ៍សាត់។

១៨.ឯកឧត្តម **ហ៊ួត ម៉ុនណារី** រដ្ឋលេខាធិការជួយរដ្ឋមន្ត្រីទទួលបន្ទុកលើការងារនាយកដ្ឋានផ្សព្វផ្សាយកសិកម្ម និងមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទរាជធានីភ្នំពេញ និងខេត្តកណ្តាល។ ក្នុងការជួយដឹកនាំលើការងារនេះប្រកបដោយប្រសិទ្ធភាពខ្ពស់ ឯកឧត្តម **ហ៊ួត ម៉ុនណារី** មានឯកឧត្តម **ចាន់ សារុទ្ធ** អនុរដ្ឋលេខាធិការ ជាជំនួយការ។

**ប្រការ៤.-**

សេចក្តីសម្រេចស្តីពីរបៀបរបបការងារនិងការបែងចែងភារកិច្ចរបស់ថ្នាក់ដឹកនាំមុនៗត្រូវចាត់ទុកជានិរាករណ៍។

**ប្រការ៥.-**

ឯកឧត្តម លោកជំទាវរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវអនុរដ្ឋលេខាធិការ ឯកឧត្តម លោកជំទាវទីប្រឹក្សាអគ្គលេខាធិការ អគ្គាធិការ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធានរដ្ឋបាលជលផល ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកៅស៊ូ ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយកនៃអគ្គនាយកដ្ឋានកសិកម្ម ប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខា-ប្រមាញ់ និងនេសាទ ប្រធានមន្ទីរកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ រាជធានី-ខេត្ត ត្រូវអនុវត្តតាមសេចក្តីសម្រេចនេះចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ថ្ងៃ ព្រហស្បតិ៍ ៧ កើត ខែ ផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
ធ្វើនៅរាជធានីភ្នំពេញ, ថ្ងៃទី ១២ ខែ ៣ ឆ្នាំ២០១៩

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល:**
- ទីស្តីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៥
- ឯកសារ កាលប្បវត្តិ